វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ
សម្ពាធសប្ប សាមន្តា[1] ទ្វង្គុលេ សត្តកម្មំ វ វត្ថុកម្មំ វ
ការាបេតព្ពំ យោ ការាបេយ្យ អាបត្តិ ថុល្លច្ចយស្សាតិ ។

(១០៦) អថខោ ភគវា ភគវតោ យថាភិរន្តំ វិហា-
រិត្វា យេន ពារាណសី តេន ចារិកំ បក្កាមិ អនុ-
បុព្ពេន ចារិកំ ចរមានោ យេន ពារាណសី តទវសរិ ។
តត្រ សុទំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ
មិគទាយេ ។ តេន ខោ បន សមយេន ពារាណសិយំ
សុប្បិយោ ច ឧបាសកោ សុប្បិយា ច ឧបាសិកា

---

๑ សមន្តា ។

ឆព្ភគ្គិយកិក្ខុគិតគ្នាថា ព្រះដ៏មានព្រះភាគទ្រង់ហាមការធ្វើសត្តកម្មហើយ ទើបឲ្យគេធ្វើវត្តិកម្មវិញ (ការបង្រឹតក្បាលឫសដូងជាតនោះដោយខ្សែ) ។ ពួកភិក្ខុណា មានសេចក្តីជ្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះពោលទោសតិះដៀល បន្ទុះបង្អាប់ថា ពួកឆព្ភគ្គិយភិក្ខុមិនសមបើនឹងឲ្យគេធ្វើវត្តិកម្មសោះ ។ លំដាប់នោះ ភិក្ខុទាំងនោះក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្ភគ្គិយភិក្ខុឲ្យគេធ្វើវត្តិកម្ម ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ បេ ។ ព្រះអង្គទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេធ្វើសត្តកម្ម ឬវត្តិកម្ម កាន់ទីជិតដោយដុំវិញ្ញៃនៃទីបង្អែតប្រមាណពីរជាប់ទេ ភិក្ខុណាឲ្យគេធ្វើ ត្រូវអាបត្តិថុល្លច្ច័យ ។

(๑๐๖) គ្រានោះ ព្រះមានព្រះភាគគង់ក្នុងក្រុងពជគិរិសមគួរតាមព្រះអធ្យាស្រ័យហើយទ្រង់យាងចេញទៅកាន់ចារិកក្រុងពារាណសី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងពារាណសីនោះ ។ បានឮថា ព្រះដ៏មានព្រះភាគគង់នៅព្រៃឥសិបតនមិគទាយវនជិតក្រុងពារាណសីនោះ ។ គ្រានោះឯង ក្នុងក្រុងពារាណសីមានជន ๒ នាក់ គឺឧបាសកឈ្មោះសុប្បិយ ๑ ឧបាសិកាឈ្មោះសុប្បិយា ๑ ជាអ្នក

ขุเภา[๑] ปสฏฺฐา ภาเยฏฺฐิ ฆายเถา ภาวเถา สงฺฆปฏฺฐา-
เถา ฯ อถโข สุปฺปิยา อุปาสิกา อาภมฺ ภตฺตา
วิภาเรน วิภารมฺ ปริเวณาย ปริเวณมฺ อุปสงฺกมิตฺวา ภิกฺขู
ปุจฺฉติ เภา ภนฺเต กิญฺจาปิ ภควตา อาหาริยตฺถาย ฯ
เตน ขฺวา ปน สมเยน อญฺญตเรน ภิกฺขุนา วิเรจนมฺ
ปีตมฺ โหติ ฯ อถโข สา ภิกฺขู สุปฺปิยมฺ อุปาสิกมฺ
เอตทโวจ ยฺวา ขฺวา ภคินิ วิเรจนมฺ ปีตมฺ อตฺถา เม
ปฏิฏฺฐานียาติ ฯ สุฏฺฐุ อยฺเย อาหาริยมฺ ลภตีติ
ยมฺ ภตฺตา อนฺเตวาสึ อาณาเปสิ ภจฺจ ภณา ปาตฺว-
มฺสมฺ ปานาหีติ ฯ เอวมฺ อยฺเยติ ขฺวา สา ปุริสา สุปฺปิ-
ยาย อุปาสิกาย ปฏิสฺสุณิตฺวา เภวลภปฺปมาณาสึ อาหิณฺฑนฺโต น อทฺทส ปาตฺวมฺสมฺ ฯ
อถโข สา ปุริสา เยน สุปฺปิยา อุปาสิ-
กา เตนุปสงฺกมิ อุปสงฺกมิตฺวา สุปฺปิยมฺ อุปาสิกมฺ
เอตทโวจ ยฺวา ขฺวา ภคินิ ปาตฺวมฺสมฺ มายา สา อชฺชาติ ฯ
อถโข สุปฺปิยาย อุปาสิกาย เอตทโหสิ ตสฺส
ขฺวา ภิกฺขุสฺส ภิกฺขุโน ปฏิฏฺฐานียมฺ อลภนฺตสฺส

---

๑ ม. ขฺวาโน ฯ

មានសេចក្តីដែរថា ជាអ្នកឲ្យទាន ជាអ្នកធ្វើការបម្រើសង្ឃ ។ លំដាប់នោះ សុប្បិយាឧបាសិកាបានទៅកាន់វត្តហើយដើរចូលទៅក្នុងវិហារក្នុងទីបរិវេណ ហើយសួរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ មានលោកម្ចាស់អគ្គណាឈឺខ្លះដែរ លោកម្ចាស់អគ្គណាត្រូវការឲ្យខ្ញុំកុណាយកបបរអ្វីមកប្រគេនដែរឬ ។ វេលានោះឯង ភិក្ខុ១រូបបានដឹកថ្នាំបញ្ចុះ ។ ភិក្ខុនោះក៏និយាយនឹងសុប្បិយាឧបាសិកាដូច្នេះថា ម្នាលនាង អាត្មាធាន់ថ្នាំបញ្ចុះ អាត្មាត្រូវការដោយសាច់ដែលមានឧជារស ។ សុប្បិយាឧបាសិកានិយាយថា ល្អហើយ លោកម្ចាស់ នឹងឲ្យគេយកមកប្រគេន (និយាយដូច្នេះហើយ) បានទៅដល់ផ្ទះហើយ ក៏បង្គាប់កូនក្មួយថា ម្នាលនាយ អ្នកចូរទៅ អ្នកចូរដេញ (ចូរទិញ) នូវសាច់សត្វដែលស្ងាប់ស្រាប់ ។ បុរសនោះបានទទួលពាក្យសុប្បិយាឧបាសិកាថា ចាស អ្នកម្ចាស់ ហើយក៏ដើរកាត់អស់ទាំងក្រុងពារាណសី មិនបានឃើញសាច់សត្វដែលស្ងាប់ស្រាប់ឡើយ ។ បុរសនោះបានចូលទៅកាន់សុប្បិយាឧបាសិកា លុះចូលទៅដល់ហើយបាននិយាយដូច្នេះនឹងសុប្បិយាឧបាសិកាថា បពិត្រអ្នកម្ចាស់ គ្មានសាច់សត្វដែលស្ងាប់ស្រាប់ទេ ព្រោះថ្ងៃនេះគ្មានគេសម្លាប់សត្វសោះ ។ លំដាប់នោះ សុប្បិយាឧបាសិកាមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើភិក្ខុឈឺនេះឯងមិនបានសាច់ដែលមានឧជារសទេ

អាពាធោ ឯ អភិវឌ្ឍិស្សតិ កាលភិរិយា ឯ ភវិស្សតិ
ន ខោ មេ តំ បដិរូបំ យាហំ បដិស្សុណិត្វា ន មាក-
បេយ្យន្តិ ។ ថោត្តនិកំ ភហេត្វា ឆារុមំ ឧក្កន្តិត្វា ឆាសិ-
យា អឆាសិ ហន្ទ ឥ ឥមំ មំសំ សម្បាទេត្វា អមុក-
ស្មឹ វិហារេ ភិក្ខូ កិលាឆោ តស្ស ឧច្ឆេបិ យោ ច មំ
បុច្ឆតិ កិលាឆាតិ បដិវេទេហីតិ ឧត្តរាសង្គេន ឆារុំ វេទេ-
ត្វា ឯវរកំ បរិសំត្វា មញ្ចភេ ឆិបដ្ឋិ ។ អថខោ សុប្បិយោ
ឧបាសភោ ឃរំ ភន្ត្វា ឆាសឹ បុច្ឆិ ភហំ សុប្បិយាតិ ។
ឯសាយ្យ ឯវរភេ ឆិបដ្ឆាតិ ។ អថខោ សុប្បិយោ ឧបា-
សភោ យេន សុប្បិយា ឧបាសិភា តេនុបសង្កមិ ឧប-
សង្កមិត្វា សុប្បិយំ ឧបាសិភំ ឯតទវោច ភិស្ស ឆិ-
បដ្ឋាសីតិ ។ កិលោឆម្ហីតិ ។ ភិន្តេ អាពាធោតិ ។ អ-
ថខោ សុប្បិយោ ឧបាសិភា សុប្បិយស្ស ឧបាសភស្ស
ឯតមត្ថំ អាវេទេសិ ។ អថខោ សុប្បិយោ ឧបាស-
ភោ អច្ចរិយំ វត ភោ អព្ភុតំ វត ភោ យាវ សត្ថាយំ

អាពាធក៏រឹងរឹតតែចំរើនទ្បើង ថ្ងមួយទទឹងឆ្ងើកាលកិរិយាទៅមិនខាន (ឥឡូវ) អាត្មាអញ បានទទួលប្តេជ្ញាថាទឹងប្រគេនសាច់ ដល់ត្រឡប់ជាមិនឲ្យគេយកទៅប្រគេនវិញ កិច្ចនោះមិនសមគួរដល់អញសោះ ។ សុប្បិយាឧបាសិកាក៏ចាប់យកគាំបិតសម្រាប់ហាន់សាច់មកអោសាច់ភ្លៅ(របស់ខ្លួន) ហើយហុចឲ្យទៅទាសីថា ហ៎ ហាងឯងចូរយកសាច់នេះទៅចាត់ចែងហើយយកទៅប្រគេនដល់កិក្ខុឈឺក្នុងវិហារឯណោះចុះ ម្យ៉ាងទៀត (បើមាន) កិក្ខុណាសួរកអញ នាងឯងចូរទូលលោកថាអញឈឺ (និយាយផ្តាំដូច្នេះហើយ) បានរុំភ្លៅដោយសម្ពត់សម្រាប់បង្អែរហើយចូលទៅក្នុងបន្ទប់ ដេកលើគ្រែ ។ លំដាប់នោះ សុប្បិយឧបាសកបានទៅកាន់ផ្ទះហើយសួរទាសីថា នាងសុប្បិយាទៅណា ។ ទាសីនោះប្រាប់ថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់នោះសម្រាន្តក្នុងបន្ទប់ ។ លំដាប់នោះ សុប្បិយឧបាសកបានចូលទៅរកសុប្បិយាឧបាសិកា លុះចូលទៅដល់ហើយសួរសុប្បិយាឧបាសិកាយ៉ាងនេះថា ព្រោះហេតុអ្វីបានជានាងដេក ។ សុប្បិយាឧបាសិកាឆ្លើយថាខ្ញុំឈឺ ។ សុប្បិយឧបាសកសួរថា នាងឈឺអ្វី ។ ទើបសុប្បិយាឧបាសិកាប្រាប់សេចក្តីនុ៎ះដល់សុប្បិយឧបាសក (ដោយសព្វគ្រប់) ។ លំដាប់នោះ សុប្បិយឧបាសកគិតថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ ចំឡែកពេកណាស់ សុប្បិយា

សុប្បិយោ បសន្នោ យត្រ ហិ នាម អត្តនោបិ មំសានំ បរិភុត្តានំ កាំ បនិមាយ(๑) អញ្ញំ កញ្ចិ អនេយ្យំ ភ-
ិក្ខុសតីតំ មាឡ្ហោ ឧទក្កោ យេន ភគវា តេនុបសង្កមិ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។
ឯកមន្តំ និសិន្នោ ខោ សុប្បិយោ ឧបាសកោ ភគ-
វន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ
ភត្តំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា
តុណ្ហីភាវេន ។ អថខោ សុប្បិយោ ឧបាសកោ ភគវ-
តោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេ-
ត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សុប្បិយោ
ឧបាសកោ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនី-
យំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អា-
រោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ
ភគវា បុព្ពណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន
សុប្បិយស្ស ឧបាសកស្ស និវេសនំ តេនុបសង្កមិ ឧប-
សង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធិំ ភិក្ខុសង្ឃេន ។
អថខោ សុប្បិយោ ឧបាសកោ យេន ភគវា តេនុបសង្កមិ

---

๑ ម, កិម្បន ឥមាយ ។

ឧបាសិកានេះជាស្រីមានសទ្ធាជ្រះថ្លាមែន អម្បាលសាច់របស់ខ្លួនគង់តែបង់បាន ចំណង់បើវត្ថុតិចតួចឯទៀត ឧបាសិកានេះនឹងមិនឲ្យដូចម្តេចបានគិតដូច្នេះហើយក៏មានចិត្តរីករាយខ្ពស់ឡើង បានចូលទៅគាល់ព្រះដ៏មានព្រះភាគលុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ។ លុះសុប្បិយឧបាសកអង្គុយក្នុងទីសមគួរហើយបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគព្រមទាំងព្រះភិក្ខុសង្ឃនិមន្តទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក។ ព្រះមានព្រះភាគទ្រង់ទទួលដោយការៈស្ងៀម។ លំដាប់នោះសុប្បិយឧបាសកបានដឹងថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ។ លុះកន្លងរាត្រីនោះទៅហើយសុប្បិយឧបាសកក៏បានតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តមហើយ ក៏ឲ្យមនុស្សទៅក្រាបបង្គំទូលកាលសមគួរចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពេលសមគួរហើយ ភត្តសម្រេចហើយ។ គ្រានោះ វេលាព្រឹកព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយប្រដាប់ដោយចីវរយាងទៅកាន់ផ្ទះសុប្បិយឧបាសក លុះយាងទៅដល់ហើយគង់លើអាសនៈដែលគេរៀបចំថ្វាយមួយអន្ទឹងដោយភិក្ខុសង្ឃ។ វេលានោះ សុប្បិយឧបាសកបានចូលទៅគាល់

อุปสงฺกมิตฺวา ภควนฺตํ อภิวาเทตฺวา ปฐมนฺตํ อฏฺฐาสิ ฯ ปฐมนฺตํ ปิตา ขฺวา สุปฺปิยํ อุปาสกํ ภควา ปฏิจฺเจว กมฺมํ สุปฺปิยาติ ฯ ตีณาปา ภควาติ ฯ เตนหิ อาคจฺฉตูติ ฯ น ภควา อุสฺสหตีติ ฯ เตนหิ ปริกฺขเตฺตปิ อาเนถาติ ฯ อถขฺวา สุปฺปิยา อุปาสิกา สุปฺปิยํ อุปาสิกํ ปริกฺขเตฺต อาเนสิ ฯ ตสฺสา สหา อสฺสเนน ภควาโต ตาวมหา วณฺโณ ปฺปชฺชิ อโหสิ สุขุมา โลมชาโต ฯ อถขฺวา สุปฺปิยา จ อุปาสิกา สุปฺปิยา จ อุปาสิกา อฺญมฺญํ ปฏิ เอวํ อฺตฺถ ปฏิ เอวํ ตถาคตสฺส มหาปุริสลกฺขณา มหาปุริสาติ ยเตฺร หิ นาม สหา อสฺสเนน ภควาโต ตาวมหา วณฺโณ ปฺปชฺชิ ภวิสฺสติ สุขุมา โลมชาโตติ หฏฺฐา อุทคฺคา พุทฺธปฺปมุขํ ภิกฺขุสงฺฆํ ปณีเตน ขาทนียเตน โภชนียเตน

ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីសមគួរ។ លុះសុប្បិយឧបាសកឈរនៅក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់មានបន្ទូលសួរដូច្នេះថា នាងសុប្បិយានៅក្នុងទីណា។ សុប្បិយឧបាសកក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ នាងសុប្បិយាឈឺ។ ព្រះអង្គទ្រង់មានបន្ទូលថា បើដូច្នោះ (ឲ្យ) នាងសុប្បិយាចូលមក។ សុប្បិយឧបាសកក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ នាងសុប្បិយាមិនអាចនឹងមកបានទេ។ ព្រះអង្គទ្រង់ត្រាស់ថា បើដូច្នោះ អ្នកចាំងឡាយចូរគ្រាប់នាំយកមក។ លំដាប់នោះ សុប្បិយឧបាសកបានគ្រាប់សុប្បិយាឧបាសិកានាំមកថ្វាយ។ និមិត្តតែព្រះមានព្រះភាគទ្រង់ទតឃើញ (កាលណា) ដំបៅរបស់នាងដែលធំដល់ម្ល៉ោះ ក៏ដុះសាច់សះជាមានសម្បុរល្អ មានពេមដុះពេញឡើងវិញមួយរំពេច។ លំដាប់នោះ សុប្បិយឧបាសកនឹងសុប្បិយាឧបាសិកាបាននិយាយគ្នាថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ បំផ្លែកពេកណាស់ ព្រះតថាគតមានបុគ្គលិនមានអានុភាពច្រើន គ្រាន់តែព្រះអង្គទ្រង់ឆាន់ទតឃើញមួយរំពេច ដំបៅដែលធំដល់ម្ល៉ោះក៏ដុះសាច់សះជាមានសម្បុរល្អមានពេមដុះពេញឡើងវិញ (អ្នកចាំងនោះ)មានចិត្តរីករាយខ្ពស់ឡើង ក៏អង្គាសខាទនីយភោជនីយាហារ

สหาตฺถา สนฺตปฺปิตฺวา สมฺปวาเรตฺวา ภควนฺตํ ภุตฺตาวึ ๑ ๑ ๑

(បន្ថែមចំអាប) ដ៏ឆ្ងាញ់ពីសាវដោយ ។ ចំពោះព្រះកិកុសង្ឃមាន
ព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រែកែកលែង
ទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះ
ហស្តទៅក្នុងបាត្រហើយ ក៏នាំគ្នាអង្គុយក្នុងទីសមគួរ ។ លំដាប់នោះ ព្រះ
មានព្រះភាគបានញុំាងសុប្បិយឧបាសកនឹងសុប្បិយាឧបាសិកា ឲ្យឃើញ
ប្លាស ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ
ក៏ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

(១០៧) ព្រោះនិទានេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ
ទ្រង់ឲ្យប្រជុំកិកុសង្ឃហើយត្រាស់សួរពួកកិកុថា ម្នាលកិកុទាំងឡាយ កិកុ
ណាសូមសាប់អំពីសុប្បិយាឧបាសិកា ។ កាលបើព្រះដ៏មានព្រះភាគ
ត្រាស់សួរយ៉ាងនេះហើយ កិកុនោះក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះ
ថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានសូមសាប់អំពីសុប្បិយាឧបា-
សិកា ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកុ អ្នកឲ្យគេនាំយកសាប់
មកហើយឬនៅ ។ កិកុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ
ខ្ញុំព្រះអង្គបានឲ្យគេនាំយកសាប់នោះមកហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា

ตุ์ กิตฺตเต ฯ ปริกุญฺชมา กตกาเต ฯ ปฏิเวกฺขิ ตุ์ กิตฺตเต ฯ ฉามา กตกา ปฏิเวกฺขิฏฺฐ ฯ ริตรหิ ตุโฺก กตกา กเฐ หิ ฉาม ตุ์ เมาะยปุริส อปฺปฏิเวกฺขิตฺวา มิสา ปริกุญฺชิสฺสสิ มนุสฺสมิสา เอา ตยา เมาะย-ปุริส ปริกุตฺตุ์ เนตา เมาะยปุริส อปฺปสชฺชาย ก ปสาทาย ฯ เป ฯ ริตรหิตฺวา ธมฺมี กเฐ กตฺวา กิตฺตุ อามนฺเตสิ สนฺติ กิตฺตเว มนุสฺสา สทฺธา ปสนฺนา เตหิ อตฺตโนปิ มิสานิ ปริจฺจตฺตานิ น กิตฺตเว มนุสฺส-มิสา ปริกุญฺชิตพฺพ์ เยา ปริกุญฺเชยฺย อาปตฺติ ถุลฺลจฺจ-ยสฺส ฯ น จ กิตฺตเว อปฺปฏิเวกฺขิตฺวา มิสา ปริกุญฺชิตพฺพ์ เยา ปริกุญฺเชยฺย อาปตฺติ ทุกฺกฏสฺสาติ ฯ

[๑๐๘] เตน เอา ปน สมเยน ราชา หตฺถี มาเรติ ฯ มนุสฺสา ทุฏฺฐิกฺเก หตฺถิมิสา ปริกุญฺชิตฺวา กิตฺตุ์ ปิณฺฑาย จรนฺตา หตฺถิมิสา เนนฺติ ฯ กิตฺตุ หตฺถิมิสา

ម្នាលកិកុ្ខ អ្នកបានឆាន់ហើយឬនៅ ។ កិកុ្ខនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានឆាន់ហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកុ្ខ (មុនដែលនឹងឆាន់) អ្នកបានពិចារណាដែរឬទេ ។ កិកុ្ខនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនបានពិចារណាទេ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងមិនសមបើនឹងមិនពិចារណាហើយហ៊ានឆាន់សាច់ (ដូច្នេះ) សោះ ម្នាលមោឃបុរស អ្នកឯងឆាន់សាច់មនុស្សពិតហើយ ម្នាលមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនជ្រះថ្លាទេ ។បេ។ ទ្រង់តិះដៀលរួចហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅកិកុ្ខទាំងឡាយមកថា ម្នាលកិកុ្ខទាំងឡាយ ពួកមនុស្សដែលមានសទ្ធា មានសេចក្តីជ្រះថ្លា មនុស្សទាំងនោះសូម្បីតែសាច់របស់ខ្លួនឯងក៏គង់នឹងលះបង់មិនបាន ម្នាលកិកុ្ខទាំងឡាយ កិកុ្ខមិនត្រូវឆាន់សាច់មនុស្សទេ កិកុ្ខណាឆាន់ ត្រូវអាបត្តិថុល្លច្চ័យ ។ ម្យ៉ាងទៀត ម្នាលកិកុ្ខទាំងឡាយ កិកុ្ខមិនបានពិចារណាជាមុនហើយ មិនត្រូវឆាន់សាច់ទេ កិកុ្ខណាឆាន់ត្រូវអាបត្តិទុក្កដ ។

(๑๐๘) សម័យនោះឯង មានដំរីរបស់ស្តេចស្វាប់ជាច្រើន ។ ចួនជាវេលាស្រុកអត់ជាយ មនុស្សទាំងឡាយនាំគ្នាសីសាច់ដំរី កំបានប្រគេនសាច់ដំរីដល់ពួកកិកុ្ខដែលត្រាច់ទៅបិណ្ឌបាត ។ កិកុ្ខទាំងឡាយ

ปริกุญฺฉติ ฯ มนุสฺสา ขุชฺฌายนฺติ ขียนฺติ วิหาเยนฺติ กถํ หิ นาม สมณา สกฺยปุตฺติยา หตฺถิมํสํ ปริกุญฺ-ฉิสฺสนฺติ ภวิสฺสติ หตฺถี สเจ ภวา ชาเนยฺย น เตสํ[๑] อตฺตมโน อสฺสาติ ฯ ภควาโต ฯตมตฺถํ อาโรเจสุ ฯ น ภิกฺขเว หตฺถิมํสํ ปริกุญฺเฉตพฺพํ โย ปริกุญฺเฉยฺย อาปตฺติ ทุกฺกฏสฺสาติ ฯ เตน โข ปน สมเยน ราชา อสฺส มารุฬฺโห ฯ มนุสฺสา ขุพฺภิกฺเข อสฺสมํสํ ปริกุญฺฉนฺติ ภิกฺขูนํ ปิณฺฑาย จรนฺตานํ อสฺสมํสํ เทนฺติ ฯ ภิกฺขู อสฺสมํสํ ปริกุญฺฉนฺติ ฯ มนุสฺสา ขุชฺฌายนฺติ ขียนฺติ วิหาเยนฺติ กถํ หิ นาม สมณา สกฺยปุตฺติยา อสฺสมํสํ ปริกุญฺฉิสฺสนฺติ ภวิสฺสติ อสฺส สเจ ภวา ชา-เนยฺย น เตสํ อตฺตมโน อสฺสาติ ฯ ภควาโต ฯตมตฺถํ อาโรเจสุ ฯ น ภิกฺขเว อสฺสมํสํ ปริกุญฺเฉตพฺพํ โย ปริ-กุญฺเฉยฺย อาปตฺติ ทุกฺกฏสฺสาติ ฯ เตน โข ปน สม-เยน มนุสฺสา ขุพฺภิกฺเข สุนขมํสํ ปริกุญฺฉนฺติ ภิกฺขูนํ

---

๑ ฉ. เทสุ ฯ

ក៏នាំគ្នាឆាន់សាច់ដំរី ។ ពួកមនុស្សពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណសក្យបុត្តមិនសមបើនឹងហ៊ានឆាន់សាច់ដំរីសោះ ដំរីក៏ជាអគ្គ (យាន) របស់ស្តេច បើស្តេចទ្រង់ជ្រាប មុខជាខ្ញាល់នឹងកិក្ខុពាំងនោះមិនខាន ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុពាំងឆ្មាយ កិក្ខុមិនត្រូវឆាន់សាច់ដំរីទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង (មាន) សេះរបស់ស្តេចស្លាប់ជាច្រើន ។ ចួនជាវេលាស្រុកអត់ជាយ មនុស្សពាំងឆ្មាយនាំគ្នាស៊ីសាច់សេះ ក៏ជាន់ប្រគេនសាច់សេះដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុពាំងឆ្មាយក៏នាំគ្នាឆាន់សាច់សេះ ។ ពួកមនុស្សពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណសក្យបុត្តមិនសមបើនឹងហ៊ានឆាន់សាច់សេះទេ ព្រោះសេះជាអគ្គ (យាន) របស់ស្តេចដែរ បើស្តេចទ្រង់ជ្រាបមុខជាខ្ញាល់នឹងភិក្ខុពាំងនោះមិនខាន ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុពាំងឆ្មាយ ភិក្ខុមិនត្រូវឆាន់សាច់សេះទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង វេលាស្រុកអត់ជាយ មនុស្សពាំងឆ្មាយនាំគ្នាស៊ីសាច់ឆ្កែ ក៏ជាន់ប្រគេនសាច់ឆ្កែដល់ពួកភិក្ខុដែលត្រាច់ទៅ

បិណ្ឌាយ ចរន្តានំ សុនខមំសំ ខេត្តំ ។ តំក្ខ សុន-
ខមំសំ បរិភុញ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិចា-
ចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា សុន-
ខមំសំ បរិភុញ្ជិស្សន្តិ ជេកុដ្ឋោ សុនខោ បដិក្កូលោតិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន តំក្ខវ សុនខមំសំ
បរិភុញ្ជិតព្ពំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។
តេន ខោ បន សមយេន មនុស្សា ទុព្ភិក្ខេ អហិ-
មំសំ បរិភុញ្ជន្តិ តិក្ខត្តុំ បិណ្ឌាយ ចរន្តានំ អហិមំសំ
ខេត្តំ ។ តំក្ខ អហិមំសំ បរិភុញ្ជន្តិ ។ មនុស្សា
ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម សមណា
សក្យបុត្តិយា អហិមំសំ បរិភុញ្ជិស្សន្តិ ជេកុដ្ឋោ អហិ
បដិក្កូលោតិ ។ សុបស្សាបិ ជាតកជា យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯតមត្ថំ
អដ្ឋាសិ ។ ឯតមត្ថំ បិតោ ខោ សុបស្សា ជាតកជ
ភគវន្តំ ឯតទវោច សន្តិ ភន្តេ ជាតា អសទ្ធា អប្ប-
សន្នា តេ អប្បមត្តកេបិ តិក្ខ វិហេឋេយ្យុំ សាធុ
ភន្តេ អយ្យា អហិមំសំ ន បរិភុញ្ជេយ្យុន្តិ ។ អថខោ

ភេសជ្ជក្ខន្ធកៈ ពោលអំពីសាច់ដែលមិនគួរ

បិណ្ឌបាត ។ កិក្ខុទាំងឡាយក៏នាំគ្នាធាន់សាច់ឆ្កែ ។ ពួកមនុស្សពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណសក្យបុត្តមិនសមបើនឹងហាន ធាន់សាច់ឆ្កែសោះ ព្រោះឆ្កែជាសត្វគួរខ្ពើមរអើម ។ កិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិក្ខុទាំងឡាយ កិក្ខុមិនត្រូវធាន់សាច់ឆ្កែទេ កិក្ខុណាធាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពេលស្រុកអត់ឃ្មុំ មនុស្សទាំងឡាយស៊ីសាច់ពស់ ក៏ចាប់ចែនសាច់ពស់ដល់ពួកកិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ កិក្ខុទាំងឡាយក៏នាំគ្នាធាន់សាច់ពស់ ។ ពួកមនុស្សពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណសក្យបុត្តមិនសមបើនឹងហានធាន់សាច់ពស់សោះ ព្រោះពស់ជាសត្វគួរខ្ពើមរអើម ។ ចំណែកខាងស្តេចនាគឈ្មោះសុបស្សបានចូលទៅគាល់ព្រះដ៏មានព្រះ-ភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះមានព្រះភាគហើយឋិតនៅក្នុងទីសមគួរ ។ លុះសុបស្សនាគពឋិតនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន នាគទាំងឡាយជាសត្វគ្មានសទ្ធា គ្មានសេចក្តីជ្រះថ្លាទេ ក្រែងពួកនាគទាំងនោះបៀត-បៀនកិក្ខុទាំងឡាយខ្លះមិនខាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរ សូមកុំឲ្យលោកម្ចាស់ទាំងឡាយធាន់សាច់ពស់ឡើយ ។ លំដាប់នោះ

ภควา สุปสฺสึ ราชกุมารํ ธมฺมิยา กถาย สนฺทสฺเสสิ สมาทปเยสิ สมุตฺเตชเยสิ สมฺปหํเสสิ ฯ อถโข สุปสฺสี ราชกุมาโร ภควตา ธมฺมิยา กถาย สนฺทสฺสิโต สมาทปิโต สมุตฺเตชิโต สมฺปหํสิโต ภควนฺตํ อภิวาเทตฺวา ปทกฺขิณํ กตฺวา ปกฺกามิ ฯ อถโข ภควา ฯตสฺมึ ขเณ ฯตสฺมึ มุหุตฺเต อุทานวเสน ธมฺมึ กถึ กตฺวา ภิกฺขู อามนฺเตสิ น ภิกฺขเว อหิเตสินา ปริกุญฺเตน ภวิตพฺพํ โย ปริกุญฺเยฺย อาปตฺติ ทุกฺกฏสฺสาติ ฯ เตน โข ปน สมเยน ลุทฺธกา[๑] สีหึ หนฺตฺวา สีหเสสกํ ปริกุญฺฉิ ภิกฺขูนํ ปิฏฺฐิยา จรนฺตานํ สีหเสสกํ เธติ ฯ ภิกฺขู สีหเสสกํ ปริกุญฺเตฺวา อาเรเก วิหรนฺติ ฯ สีหา สีหเสสเกน ภิกฺขู ปริหาเรนฺติ ฯ ภควาโต ฯตมตฺถํ อาโรเจสุ ฯ น ภิกฺขเว สีหเสสกํ ปริกุญฺเตฺวา ภวิตพฺพํ โย ปริกุญฺเยฺย อาปตฺติ ทุกฺกฏสฺสาติ ฯ เตน โข ปน สมเยน ลุทฺธกา ฉฺปิ หนฺตฺวา ฉฺปิ สเสสกานิ ปริกุญฺฉิ ภิกฺขูนํ ปิฏฺฐิยา จรนฺตานํ ฉฺปิ สเสสกานิ เธติ ฯ ภิกฺขู ฉฺปิ สเสสกานิ ปริกุญฺเตฺวา อาเรเก วิหรนฺติ ฯ

---

๑ ฉ. ลุทฺทกา ฯ

ព្រះមានព្រះភាគញុំងសុបស្សនាគារជ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ។ លុះសុបស្សនាគារជដែលព្រះដ៏មានព្រះភាគ ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ផ្ចាយបន្ទំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រោះនិទានេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនាន់សាច់ពស់ទេ ភិក្ខុណានាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់សត្វសីហៈហើយសុីសាច់សីហៈ ក៏បានប្រគេនសាច់សីហៈដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុនាន់សាច់សីហៈហើយក៏ទៅនៅក្នុងវិត ។ ពួកសត្វសីហៈឆ្កុំកូនសាច់សីហៈ ក៏សម្លាប់ភិក្ខុជាច្រើន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនាន់សាច់សីហៈទេ ភិក្ខុណានាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់ខ្លាធំហើយសុីសាច់ខ្លាធំ ក៏បានប្រគេនសាច់ខ្លាធំដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុនាន់សាច់ខ្លាធំហើយទៅនៅក្នុងវិត ។

ព្យក្ឃា ព្យក្ឃមំសកន្តេន កិក្ខូ បរិភាសិតព្ពំ ។ កតរាសោ
ឯតមត្ថំ អារោចេសុំ ។ ន កិក្ខវេ ព្យក្ឃមំសំ បរិភុញ្ជិតព្ពំ
យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ
បន សមយេន លុទ្ទកា ទីបិំ ហន្ត្វា ទីបិមំសំ បរិ-
ភុញ្ជន្តិ កិក្ខូនំ បិណ្ឌាយ ចរន្តានំ ទីបិមំសំ ទេន្តិ ។
កិក្ខូ ទីបិមំសំ បរិភុញ្ជិត្វា អរញ្ញេ វិហរន្តិ ។ ទីបិ ទីបិ-
មំសកន្តេន កិក្ខូ បរិភាសិតព្ពំ ។ កតរាសោ ឯតមត្ថំ
អារោចេសុំ ។ ន កិក្ខវេ ទីបិមំសំ បរិភុញ្ជិតព្ពំ យោ
បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន
សមយេន លុទ្ទកា អច្ឆំ ហន្ត្វា អច្ឆមំសំ បរិភុញ្ជន្តិ
កិក្ខូនំ បិណ្ឌាយ ចរន្តានំ អច្ឆមំសំ ទេន្តិ ។ កិក្ខូ
អច្ឆមំសំ បរិភុញ្ជិត្វា អរញ្ញេ វិហរន្តិ ។ អច្ឆា អច្ឆមំស-
កន្តេន កិក្ខូ បរិភាសិតព្ពំ ។ កតរាសោ ឯតមត្ថំ អារោចេ-
សុំ ។ ន កិក្ខវេ អច្ឆមំសំ បរិភុញ្ជិតព្ពំ យោ បរិភុញ្ជេយ្យ
អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន
លុទ្ទកា តរច្ឆំ ហន្ត្វា តរច្ឆមំសំ បរិភុញ្ជន្តិ កិក្ខូនំ

ភេសជ្ជក្ខន្ធកៈ ពោលអំពីសាច់ដែលមិនគួរ

ពួកខ្លាធំបានឆុំកូនសាច់ខ្លាធំក៏សម្លាប់កិកុជាច្រើន ។ កិកុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកុទាំងឡាយ កិកុមិនត្រូវឆាន់សាច់ខ្លាធំទេ កិកុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់ខ្លាដំបងហើយស៊ីសាច់ខ្លាដំបង ក៏បានប្រគេនសាច់ខ្លាដំបងដល់ពួកកិកុដែលត្រាច់ទៅបិណ្ឌបាត ។ ពួកកិកុឆាន់សាច់ខ្លាដំបងហើយ ក៏ទៅនៅក្នុងវៃព្រៃ ។ ពួកខ្លាដំបងបានឆុំកូនសាច់ខ្លាដំបងក៏សម្លាប់កិកុជាច្រើន ។ កិកុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិកុទាំងឡាយ កិកុមិនត្រូវឆាន់សាច់ខ្លាដំបងទេ កិកុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់សត្វខ្លាឃ្មុំហើយស៊ីសាច់ខ្លាឃ្មុំ ក៏បានប្រគេនសាច់ខ្លាឃ្មុំដល់ពួកកិកុដែលត្រាច់ទៅបិណ្ឌបាត ។ ពួកកិកុឆាន់សាច់ខ្លាឃ្មុំហើយក៏ទៅនៅក្នុងវៃព្រៃ ។ ពួកខ្លាឃ្មុំបានឆុំកូនសាច់ខ្លាឃ្មុំហើយក៏សម្លាប់កិកុជាច្រើន ។ កិកុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កិកុមិនត្រូវឆាន់សាច់ខ្លាឃ្មុំទេ កិកុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់សត្វឆ្កែវៃព្រៃហើយស៊ីសាច់ឆ្កែវៃព្រៃ ក៏បានប្រគេនសាច់

ปิณฺฑาย จรนฺตสฺส สญฺญมตฺถาย เจตสา ฯ ภิกฺขุ สญฺญมตฺถาย ภุญฺชิตพฺพา อญฺเญ วิหารนฺติ ฯ สญฺญา สญฺญมตฺถาย เจตสา ภิกฺขุ ปริภาเตนฺติ ฯ ภควาเตา ปฏิสงฺขา อาโรเจสุ ฯ น ภิกฺขเว สญฺญมตฺถาย ปริภุญฺชิตพฺพา โย ปริภุญฺเชยฺย อาปตฺติ ทุกฺกฏสฺสาติ ฯ

สุปฺปิยภาณวาโร ทุติโย ฯ

[๑๐๙] อถโข ภควา พาราณสิยํ ยถาภิรนฺตํ วิหริตฺวา เยน อนฺธกวินฺทํ เตน จาริกํ ปกฺกามิ มหตา ภิกฺขุสงฺฆเน สทฺธึ อฑฺฒเตลสเตหิ ภิกฺขุสเตหิ ฯ เตน โข ปน สมเยน ฉานปทา มนุสฺสา พหุ โลณญฺจ เตลญฺจ ตณฺฑุลญฺจ ขาทนียญฺจ สกเฏสุ อาโรเปตฺวา ตุนฺทวฺยมุขสฺส ภิกฺขุสงฺฆสฺส ปิฏฺฐโต ปิฏฺฐโต อนุพนฺธา โหนฺติ ยถา ปฐมาย ลภิสฺสาม ตถา ภตฺตํ ภิกฺขาจริยาย ปญฺญเปตฺวานิ จ วิยาสาเทสฺสามานิ ฯ อถโข ภควา อนุปุพฺเพน จาริกํ จรมาโน เยน อนฺธกวินฺทํ ตทวสริ ฯ อถโข อญฺญตรสฺส พฺราหฺมณสฺส ปฐมาย อลภนฺตสฺส ฉาตชฺฌตฺตสฺส อโหสิ อนิกามา[๑] เม ภูมิ

๑ ฉ. อกามา ฯ

ឆ្កែត្រៃដល់ពួកកិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ កិក្ខុទាំងឡាយធាន់សាច់ឆ្កែត្រៃហើយក៏ទៅនៅក្នុងត្រៃ ។ ពួកឆ្កែត្រៃបានធុំក្លិនសាច់ឆ្កែត្រៃហើយក៏សម្លាប់កិក្ខុជាច្រើន ។ កិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិក្ខុទាំងឡាយ កិក្ខុមិនត្រូវធាន់សាច់ឆ្កែត្រៃទេ កិក្ខុណាធាន់ ត្រូវអាបត្តិទុក្កដ ។

ចប់ សុប្បិយភាណវារៈ ទី ២ ។

(๑๐๙) គ្រានោះ ព្រះដ៏មានព្រះភាគគង់ទៀបក្រុងពារាណសីសម្គួរតាមព្រះអធ្យាស្រ័យហើយ ក៏យាងចេញទៅកាន់ចារិកនៃអន្តរាវិនូប្រទេស ជាមួយនឹងកិក្ខុសង្ឃជាច្រើនប្រមាណមួយពាន់ពីររយហាសិបរូប ។ សម័យនោះឯង ពួកមនុស្សអ្នកជនបទបានផ្តុំកអម្បិលខ្លះ ស្រែងខ្លះ អង្កាខ្លះ ខាទនីយៈខ្លះ ក្នុងវរេះទាំងឡាយហើយក៏បរទៅតាមក្រោយ ។ កិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ពួកមនុស្សអ្នកស៊ីដែលប្រមាណជុំវិញនាក់ក៏គិតគ្នាថា (បើ) ពួកយើងបានលំដាប់ (វេន) នៃកត្តុកង្គកាលណា នឹងធ្វើកត្តុកង្គកាលនោះ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ក៏បានដល់ទៅអន្តរាវិនូប្រទេសនោះ ។ លំដាប់នោះ កាលព្រាហ្មណ៍ម្នាក់មិនបានលំដាប់ (វេន) នៃកត្តុ ក៏មានសេចក្តីរិះគិតយ៉ាងនេះថា អាត្មាអញបានដើរតាមកិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន

មាសានំ ពុទ្ធប្បមុខំ តិក្ខុសង្ឃំ អនុពន្ធិស្សយនា បដិថា-
ដឹ លភិស្សាមិ តនា កតុំ ការិស្សាមីតិ ន ច មេ បដិថាដិ
លព្ភតិ អហាញ្ហិ ឯកកោ ពហុ ច មេ ឃរាសនេ
ហាយតិ យន្នូនាហំ កត្តព្ពំ ឯលោកេយ្យំ យំ កត្តព្ពេ
ឆាស្ស តំ បដិយាទេយ្យន្តិ ។ អថខោ សោ ព្រាហ្មណោ
កត្តព្ពំ ឯលោកេន្តោ ទ្វេ ឆាន្តិស្ស យាគុញ្ច មធុគោឡ-
កញ្ច ។ អថខោ សោ ព្រាហ្មណោ យេនាយស្មា អានន្ទោ
តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច
ឥធ មេ ភោ អានន្ទ បដិថាដឹ អលភន្តស្ស ឯតទហោសិ
អដិតាដិ ខោ មេ ទ្វេ មាសានំ ពុទ្ធប្បមុខំ តិក្ខុសង្ឃំ
អនុពន្ធិស្ស យនា បដិថាដឹ លភិស្សាមិ តនា កតុំ ការិ-
ស្សាមីតិ ន ច មេ បដិថាដិ លព្ភតិ អហាញ្ហិ ឯកកោ
ពហុ ច មេ ឃរាសនេ ហាយតិ យន្នូនាហំ កត្តព្ពំ
ឯលោកេយ្យំ យំ កត្តព្ពេ ឆាស្ស តំ បដិយាទេយ្យន្តិ

ជាង ๒ ខែហើយ ដោយប៉ងថា បើអាត្មាអញបានលំដាប់ (វេន) នៃ
កត្តកង់កាលណា នឹងធ្វើកត្តកង់កាលនោះ ឥឡូវលំដាប់ (វេន) នៃកត្ត
អាត្មាអញមិនទាន់បាននៅឡើយ ខ្លួនអញទៀតសោតក៏តែម្នាក់ឯង គាំង
ប្រយោជន៍ខាងឃ្លាសរបស់អាត្មាអញទៀតក៏សាបសូន្យទៅជាច្រើន បើ
ដូច្នោះមានតែគួរអាត្មាអញទៅត្រួតមើលភេងកត្ត រត្តិណាគ្មានកង់ភេងកត្ត
អាត្មាអញក៏នឹងតាក់តែងនូវវត្តនោះ ។ លុះដល់ព្រាហ្មណ៍នោះទៅ
មើលភេងកត្តក៏មិនឃើញវត្តពីរយ៉ាង គឺបបរនឹងនំមានរសផ្អែមឡើយ[1] ។
ទើបព្រាហ្មណ៍នោះចូលទៅកាន់ព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់
ហើយនិយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចំរើន
កាលខ្ញុំកុរណាមិនបានលំដាប់ (វេន) នៃកត្តកង់ទីនេះ ក៏មានសេចក្តីត្រិះរិះ
យ៉ាងនេះថា អាត្មាអញដើរតាមកិក្កុសង្ឃមានព្រះពុទ្ធជាប្រធានជាង ๒ ខែ
ហើយ ដោយប៉ងថា (បើ)អាត្មាអញបានលំដាប់(វេន)នៃកត្តកង់ពេលណា
នឹងធ្វើកត្តកង់ពេលនោះ ឥឡូវអាត្មាអញមិនទាន់បានលំដាប់(វេន)នៃកត្ត
នៅឡើយ ខ្លួនអញទៀតសោតក៏តែម្នាក់ឯង គាំងប្រយោជន៍ខាងឃ្លាស
របស់អញទៀតក៏សាបសូន្យទៅជាច្រើន បើដូច្នោះមានតែគួរអាត្មាអញ
ទៅត្រួតមើលភេងកត្ត រត្តិណាគ្មានកង់ភេងកត្ត អាត្មាអញនឹងតាក់តែង

---

๑ ក្នុងដីកាថា ទំនៃលេណ្ឌយដោយវត្ថុមានស្ករជាដើម ។

สเจ ขเว อยนฺ เตน อาทินฺโน ภณฺฑกฺโก ปุเนเทวเตฺวว
วทติ มยา ตุยฺหนฺ ทินฺนปุพฺพนฺ ตยา ปฏิคฺคหิตปุพฺพนฺ
สเจปิ ตสฺส ปริโภคปฺปโหนกนฺ ตสฺส ปริโภคปฺปโหนกนฺ
ปฏิคฺคเหตฺวา ปริภุญฺชิตพฺพนฺ ฯ เตนปิ พฺราหฺม-
ณา ภควนฺตนฺ ปฏิปุจฺฉิตพฺพนฺ ฯ อถโข อายสฺมา
อานนฺโท ภควโต ปตฺตมทาสิ ฯ เตนปิ
อานนฺท ปฏิคฺคเหตฺวนฺติ ฯ เตนหิ พฺราหฺมณ ปฏิ-
คฺคเหตฺวาติ ฯ อถโข สเจ พฺราหฺมโณ ตสฺส
ปตฺตสฺส อนฺตเรน ปหฺมนฺ คจฺเฉยฺย ปฏิคฺคหิตเกเยว
ปฏิคฺคหิตเกติ ภควโต อุปนาเมยฺย ปฏิคฺคณฺหาตุ
เม ภนฺเต ภควาติ ยาวตฺติกา ปฏิคฺคหิตกา ภวนฺติ ฯ เต-
นหิ พฺราหฺมณ ตีณิ ขณฺฑานิ เทหีติ ฯ ตีณิ ขณฺฑานิ ฉฑฺเฑตฺวา
น ปฏิคฺคณฺเหยฺย ฯ ปฏิคฺคณฺเหยฺย ตีณิ ขณฺฑานิ ฉฑฺเฑตฺวา ปตฺตนฺ ฯ

វត្តុនោះ (យ៉ាងនេះ) បពិត្រព្រះអានន្ទដ៏ចំរើន កាលខ្ញុំព្រះករុណា
ទៅមើលភេងកត្ត មិនបានឃើញវត្តុពីយ៉ាង គឺបបរនឹងនំមានរសផ្អែម
ឡើយ បពិត្រព្រះអានន្ទដ៏ចំរើន បើខ្ញុំករុណាតាក់តែងបបរនឹងនំមានរស
ផ្អែមមកថ្វាយ ព្រះគោតមដ៏ចំរើនទ្រង់ទទួលរបស់ខ្ញុំករុណាដែរឬ ។ ព្រះ
អានន្ទក្រាបថា ម្នាលព្រាហ្មណ៍ បើដូច្នោះចាំអាត្មាទូលសួរព្រះដ៏មានព្រះ
ភាគសិន ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុបានក្រាបបង្គំទូលសេចក្តីនុ៎ះ
ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ
ឲ្យព្រាហ្មណ៍នោះតាក់តែងចុះ ។ ទើបព្រះអានន្ទទៅក្រាបព្រាហ្មណ៍
ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរតាក់តែងចុះ ។ លុះពត្រីនោះ
កន្លងទៅហើយ ឯព្រាហ្មណ៍នោះតាក់តែងបបរនឹងនំមានរសផ្អែមជាច្រើន
ក៏បានបង្អោនថ្វាយចំពោះព្រះដ៏មានព្រះភាគហើយទូលថា សូមព្រះ
គោតមដ៏ចំរើនទ្រង់ទទួលបបរនឹងនំមានរសផ្អែមរបស់ខ្ញុំព្រះអង្គ ។ ព្រះ
ដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរប្រគេន
ដល់កិក្ខុទាំងឡាយចុះ ។ ពួកកិក្ខុរង្គើសមិនហ៊ានទទួល ។ ព្រះអង្គទ្រង់
ត្រាស់ថា ម្នាលកិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ ។

អថខោ សោ ព្រាហ្មណោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បហូតាយ យាគុយា ច មធុផាណិតេន ច សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ឆោតហត្ថំ ឯឝីតបត្តចាណឺ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ ព្រាហ្មណំ ភគវា ឯតទវោច ទសយិមេ[1] ព្រាហ្មណ អានិសំសា យាគុយា កតមេ ទស យាគុំ ទេន្តោ អាយុំ ទេតិ វណ្ណំ ទេតិ សុខំ ទេតិ ពលំ ទេតិ បដិភាណំ ទេតិ យាគុ បីតា ខុទំ បដិ-ហរតិ បិបាសំ បដិវិនោទេតិ វាតំ អនុលោមេតិ វត្ថឹ សោធេតិ អាមាវសេសំ ចាចេតិ ឥមេ ខោ ព្រាហ្មណ ទសានិសំសា យាគុយាតិ ។

(๑๑๐) យោ សញ្ញតានំ បរទត្តភោជិនំ
កាលេន សក្កច្ច ទទាតិ យាគុំ
ទសស្ស ហានានិ អនុប្បវេច្ឆតិ
អាយុញ្ច វណ្ណញ្ច សុខំ ពលញ្ច
បដិភាណមស្ស ឧបជាយតេ តតោ

---

๑ ឱ. ទសិមេ ។

ព្រាហ្មណ៍នោះអង្គាសតិក្ខសង្ឃមានព្រះពុទ្ធអង្គជាប្រធានដោយបបរទន់ៗ
មានរសផ្អែមជាច្រើនដោយដៃរបស់ខ្លួន ឲ្យឆ្អែតស្កប់ស្កល់ គ្រាតែលោក
ប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់លាងព្រះហស្ត
សើចលែងលូកទៅក្នុងបាត្រហើយ (ព្រាហ្មណ) ក៏អង្គុយក្នុងទីសមគួរ ។
លុះព្រាហ្មណ៍នោះអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់មាន
បន្ទូលដូច្នេះថា ម្នាលព្រាហ្មណ៍ អានិសង្សបបរនេះមាន ១០ យ៉ាង អា-
និសង្សបបរ ១០ យ៉ាងនោះតើដូចម្តេច គឺបុគ្គលអ្នកឲ្យបបរឈ្មោះថា ឲ្យ
អាយុ ១ ឲ្យពណ៌សម្បុរ ១ ឲ្យសេចក្តីសុខ ១ ឲ្យកំឡាំងកាយ ១ ឲ្យ
ប្រាជ្ញា ១ បបរដែលបុគ្គលហុតទៅហើយរមែងហាមយាត់សេចក្តីឃ្លាន ១
បន្ទោបង់សេចក្តីស្រេក ១ ញុំាងខ្យល់ឲ្យដើរទៅស្រួល ១ ញុំាងសរសៃ
ឲ្យស្អាត ១ ញុំាងអាហារថ្មីដ៏សេសសល់ឲ្យរលួយ ១ ម្នាលព្រាហ្មណ៍
អានិសង្សបបរមាន ១០ យ៉ាងនេះឯង ។

(๑๑๐) ជនណាបានឲ្យបបរដោយគោរពដល់ពួកសមណៈ
ដែលជាអ្នកសង្រួម អ្នកបរិភោគតែជនដែលអ្នកដទៃឲ្យ ក្នុង
កាលដ៏គួរ (ជននោះ) ឈ្មោះថា ឲ្យនូវហេតុនៃអានិសង្ស
ទាំង ១០ យ៉ាង គឺ អាយុ ១ ពណ៌សម្បុរ ១ សេចក្តីសុខ ១
កំឡាំងកាយ ១ ប្រាជ្ញារបស់បុគ្គលនោះតែងកើតឡើង ១

ខុទ្ទំ បិចាសំ ឥមេនេតំ ភតំ
សោនេតំ វត្ថំ បរិណាមេតំ ភត្តំ ។
កេសញ្ជមេតំ សុភតេន វណ្ណិតំ ។
តស្មា ហិ យាតុំ អលមេវ ជាតុំ
និច្ចំ មនុស្សេន សុខត្ថិកេន
និព្ភានិ ភ បត្ថយតា សុខានិ
មនុស្សសោភគ្គតមិច្ឆតា[1] ភតំ ។

(๑๑๑) អថខោ ភគវា តំ ព្រាហ្មណំ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បការណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ យាតុញ្ច មនុគោទ្ធកញ្ចាតិ ។

(๑๑๒) អស្សោសុំ ខោ មនុស្សា ភគវតា កិរ ភិក្ខូនំ យាតុ អនុញ្ញាតា មនុគោទ្ធកញ្ចាតិ ។ តេ កាលស្សេវ គោដ្ឋយាតុំ បដិយាទេន្តិ មនុគោទ្ធកញ្ច ។ ភិក្ខូ កាលស្សេវ គោដ្ឋយាតុយោ ជាតា មនុគោទ្ធកេន

---

๑ ម. មនុស្សសោភាគ្យតំ ។ ឥច្ឆតាតិ ពត្តព្ពេ ឥច្ឆតេ ទិស្សតិ ។

បបវរនោះតែងកំចាត់បង់សេចក្តីឃ្លាន ១ សេចក្តីស្រេក ១ នឹងញាំងខ្យល់ (ឲ្យបានដើរស្រួល) ១ ញាំងសរសៃឲ្យស្អាត ១ ញាំងកត្តឲ្យរលួយ ១។ នេះជាកេសផ្លៈដែលព្រះសុគតទ្រង់សរសើរហើយ។ ព្រោះហេតុនោះ អ្នកមានសេចក្តីត្រេកអរចង់បានសេចក្តីសុខជារបស់មនុស្សក្តី ប្រាថ្នាសេចក្តីសុខជារបស់ទិព្វក្តី ចង់បានសេចក្តីល្អរុងរឿងក្នុងមនុស្សក្តី គួរឲ្យបបវរជានិច្ចចុះ។

(១១១) លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់អនុមោទនាចំពោះព្រាហ្មណ៍នោះដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈយាងចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុនាន់) បបវនីឯនំមានរសផ្អែមបាន។

(១១២) ពួកមនុស្សបានឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតបបវនីឯនំមានរសផ្អែមដល់ភិក្ខុទាំងឡាយ (ដូច្នោះ) ហើយ។ មនុស្សទាំងនោះក៏នាំគ្នាគាក់តែងបបវកោដ្ឋ[1] នឹងនំមានរសផ្អែម ពីព្រឹកព្រហាម (មកប្រគេនភិក្ខុទាំងឡាយ)។ ពួកភិក្ខុបានឆាន់បបវកោដ្ឋ

---

១ បបវដែលគេធ្វើអំពីភោជនទាំង ៥ គឺបាយ ១ នំស្រែះ ១ នំក្បែរ ១ ត្រី ១ សាច ១ ដែលនាំឲ្យកើតបបវរណា តាមសិក្ខាបទទី ៥ នៃភោជនវគ្គ។

ច កត្តុកេ ន ចិត្តរូបំ កុញ្ជន្តិ ។ តេន ខោ បន សម-
យេន អញ្ញតរេន តវុណប្បសន្នេន មហាមត្តេន ស្វាត-
នាយ ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ និមន្តិតោ ហោតិ ។
អថខោ តស្ស តវុណប្បសន្នស្ស មហាមត្តស្ស ឯតទហោ-
សិ យន្នូនាហំ អឌ្ឍតេលសន្នំ ភិក្ខុសតានំ អឌ្ឍតេ-
លសានិ មំសថាលីសតានិ បដិយាទេយ្យំ ឯកមេកស្ស
ភិក្ខុនោ ឯកមេកំ មំសថាលិំ ឧបនាមេយ្យន្តិ ។ អថ-
ខោ សោ តវុណប្បសន្នោ មហាមត្តោ តស្សា រត្តិយា
អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា
អឌ្ឍតេលសានិ ច មំសថាលីសតានិ ភតវាតោ កាលំ
អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ
ភគវា បុព្ពណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ
យេន តស្ស តវុណប្បសន្នស្ស មហាមត្តស្ស និវេសនំ
តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ
សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ សោ តវុណប្បសន្នោ
មហាមត្តោ ភត្តុក្ខេ ភិក្ខូ បវារេសិ ។ ភិក្ខូ ឃវមាហំសុ

នឹងនំមានរសផ្អែមឆ្អែតពីព្រឹកព្រហាមហើយ លុះទៅនាន់ក្នុងភេងកត្តទៀត ក៏មិនបានឆ្ងាញ់ពីសា ។ សម័យនោះឯង មានមហាមាត្យម្នាក់ជាអ្នកមានសេចក្តីជ្រះថ្លាថ្មី (មិនទាន់មុតមាំ) បាននិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានទុកដើម្បីនាន់ក្នុងថ្ងៃស្អែក ។ លំដាប់នោះ មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះមានតែគួរអាត្មាអញគាក់តែងចង្ហាន់សាច់ចំនួនមួយពាន់ពីរយហាសិបសម្រាប់ (ឲ្យល្មម) ដល់ភិក្ខុមួយពាន់ពីរយហាសិបរូប ហើយប្រគេនចង្ហាន់សាច់មួយសម្រាប់ ។ ដល់ភិក្ខុមួយរូប ។ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ លុះកន្លងរាត្រីនោះទៅក៏បានគាក់តែងខាទនីយភោជនីយៈដ៏ខ្ពង្គម នឹងចង្ហាន់សាច់មួយពាន់ពីរយហាសិបសម្រាប់ ហើយក៏ប្រើបម្រើឲ្យទៅក្រាបបង្គំទូលពេលនាន់ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពេលនេះល្មមហើយ ភត្តសម្រេចហើយ ។ គ្រានោះ ពេលព្រឹកព្រហាមព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយប្រដាប់ដោយចាត្តនឹងចីវរយាងទៅកាន់ផ្ទះមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ លុះយាងទៅដល់ហើយទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ មួយអន្ទឹងដោយភិក្ខុសង្ឃ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះបានអង្គាសពួកភិក្ខុក្នុងភេងកត្ត ។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ អ្នកបូរ

ថោកំ អាវុសោ នេហិ ថោកំ អាវុសោ នេហីតិ ។ មា
ខោ តុម្ហេ ភន្តេ អយំ តវុណាបស្សន្ទោ មហាមត្តោតិ ថោ-
កំ ថោកំ បដិក្កណ្ហាថ ៣ហុំ មេ ខាទនីយំ ភោជនីយំ
បដិយត្តំ អឌ្ឍតេលសានិ ច មំសថាតីសតានិ ឯកមេ-
កស្ស កិក្ខុនោ ឯកមេកំ មំសថាតឹ ឧបឌាមេស្សាមិ
បដិក្កណ្ហាថ ភន្តេ យាវឌត្តន្តិ ។ ឧ ខោ មយំ អាវុសោ
ឯតំការណា ថោកំ ថោកំ បដិក្កណ្ហាម អបិច មយំ
ការុសេ្ស ភោជ្ជយាគុយា ឌានា មធុភោឌ្ឍភោឧ ច
តេឧ មយំ ថោកំ ថោកំ បដិក្កណ្ហាមាតិ ។ អថខោ
សោ តវុណាបស្សន្ទោ មហាមត្តោ ឧជ្ឈាយតិ ខីយតិ
វិបាចេតិ កថំ ហិ ឌាម ភន្តេ មយា ឯមន្តិតា អញ្ញេ
ភោជ្ជយាតុំ បរិភុញ្ជិស្សន្តិ ឧ ទានាហំ បដិពលោ យាវឌត្តំ
ឌាតុន្តិ ភុបិតោ អឧត្តមនោ អាសាឧឌាមេភ្នោ កិក្ខុំ
បត្តេ ឬរោន្តោ អភមាសិ ភុញ្ជថ ភ ហរថ ឯតិ ។ អថខោ
សោ តវុណាបស្សន្ទោ មហាមត្តោ ពុទ្ធបមុខំ កិក្ខុសង្ឃំ

ឲ្យ (កត្តិ) តែបន្តិចចុះ ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចបានហើយ ។ មហាមាត្យនិយាយថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ចាំឆ្ងាយកុំទទួលកត្តិបន្តិចបន្តួចដោយគិតថា មហាមាត្យនេះមានសេចក្តីជ្រះថ្លាខ្លាំង. នឹយកោដនីយៈ:ខ្ញុំបានចាត់ចែងគុកហើយជាច្រើន ចាំឆ្ងាន់សាច់មួយពាន់ពីរយហាសិបសម្រាប់ផង ខ្ញុំនឹងប្រគេនចង្ហាន់សាច់មួយសម្រាប់ៗ ដល់កិក្ខុមួយរូបៗបពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ចាំឆ្ងាយទទួលជាបដល់ថ្ងៃត្អូត ។ ពួកភិក្ខុនិយាយតបថា ម្នាលអាវុសោ យើងចាំឆ្ងាយទទួលកត្តិបន្តិច ។ ព្រោះហេតុប៉ុណ្ណោះក៏ដេ យើងចាំឆ្ងាយធាន់បបរគោជូនដ៏ឯំមានសេចក្តីមត្អែតអំពីព្រឹករួចហើយ ព្រោះហេតុនោះ ឆានជាយើងទទួលកត្តិតែបន្តិចៗ ។ លំជាប់នោះ មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះក៏ពោលពោសតិះដៀល បន្ទុះបង្អាប់ថា ខ្ញុំបាននិមន្តលោកម្ចាស់ចាំឆ្ងាយរួចហើយ មិនសមបើនឹងឲ្យធាន់បបរគោដ្ឋរបស់ជនឯទៀតសោះ (លោកម្ចាស់ខ្ជាចក្រែង) ខ្ញុំមិនអាចនឹងប្រគេនឲ្យធាន់ត្អែតបានឬ ។ មហាមាត្យនោះ មានសេចក្តីក្រោធគូបចិត្តច្រឡាំងនឹងចោទ កាលជាក់ច្បាស់កិក្ខុចាំឆ្ងាយពេញហើយក៏ដើរទៅនិយាយថា ពួកលោកណាចង់ធាន់ក្តីនាំយកទៅក្តី (ក៏តាមចិត្តចុះ) ។ លំជាប់នោះ មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះបានអង្គាសកិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយខាទនីយ

បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ កុត្តាវំ ទិធីតបត្តចាណឺ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ តវុណាប្បសន្នំ មហាមត្តំ ភគវា ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ តស្ស តវុណាប្បសន្នស្ស មហាមត្តស្ស អចិរប្បក្កន្តស្ស ភគវតោ អហុទេវ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យោហំ កុមិតោ អនត្តមនោ អាសាទនាបេក្ខោ កិញ្ចនំ បត្តេ ហូរេត្តោ អកមាសឺ កុញ្ជរ ភ ហារជ ភតិ កិន្តុខោ មយា ពហុំ បសុតំ បុញ្ញំ ភ អបុញ្ញំ ភតិ ។ អថខោ សោ តវុណាប្បសន្នោ មហាមត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិភាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ តវុណាប្បសន្នោ មហាមត្តោ ភគវន្តំ

កោដនីយៈដ៏ឧត្តមដោយដៃនៃខ្លួនឲ្យឆ្អែតស្កប់ស្កល់ គ្រាតែលោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេចលែងលូកព្រះហស្តទៅក្នុងបាត្រហើយ (មហាមាត្យ) ក៏អង្គុយកន្លែងសមគួរ ។ លុះមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះអង្គុយនៅកន្លែងសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ កាលព្រះដ៏មានព្រះភាគយាងចេញទៅមិនយូរប៉ុន្មាន ក៏កើតសេចក្តីរង្កៀសនឹងសេចក្តីក្តៅក្រហាយថា អាត្មាអញឥតលាភទេតើ លាភរបស់អាត្មាអញគ្មានសោះទេហ្ន៎ ទាំងអត្តភាពជាមនុស្សសោតក៏អាត្មាអញបានដោយកម្រ មិនមែនអាត្មាអញបានដោយងាយទេ (ឥឡូវ) អាត្មាអញទឹងតូចចិត្តថ្កោលទោសព្រះដ៏មានព្រះភាគ បានជាក់បាត្រកិក្ខុទាំងឡាយឲ្យពេញហើយដើរចៀសចេញទៅនិយាយថា លោកទាំងឡាយចូរធាន់ក្តីនាំយកទៅក្តី (ក៏តាមចិត្តចុះ) កម្មដែលអាត្មាអញសន្សំមកជាច្រើនហើយ (នេះ) នឹងជាបុណ្យឬជាបាបហ្ន៎ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយកន្លែងសមគួរ ។ លុះមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះអង្គុយកន្លែងសមគួរហើយ ក៏ក្រាបបង្គំទូល

ឯតទវោច ៨ឆ មយ្ហំ កន្តេ អច់របក្កន្តសទ្ទ កតរតោ
អហុនេវ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត មេ
ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ
យោហំ កុបិតោ អនត្តមនោ អាសាទនាបេក្ខោ
តំក្ខណំ បតេ បូរេន្តោ អកមាសឹ កុញ្ជ៑ ភ មារជ ភតំ
តិដ្ឋ ខោ មយា ពហុំ បសុតំ បុញ្ញំ ភ អបុញ្ញំ ភតំ
តិដ្ឋ ខោ មយា កន្តេ ពហុំ បសុតំ បុញ្ញំ ភ អបុញ្ញំ
ភតំ ។ យទក្កេន តយា អាវុសោ ស្វាតនាយ
ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ និមន្តិតោ តទក្កេន តេ ពហុំ
បុញ្ញំ បសុតំ យទក្កេន តេ ឯកមេកេន ភិក្ខុនា
ឯកមេកំ សិត្ថំ បដិក្កហិតំ តទក្កេន តេ ពហុំ បុញ្ញំ
បសុតំ សក្កា តេ អាវជ្ជិតំ ។ អថខោ សោ តវុណាម្ប-
សង្ឃោ មហាមត្តោ លាភា តវ មេ សុលទ្ធំ តវ មេ

ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន កាលដែលព្រះដ៏មានព្រះភាគយាងចេញទៅមិនយូរប៉ុន្មាន ក្នុងវេលានេះ ខ្ញុំព្រះអង្គក៏មានសេចក្តីរង្កៀសនឹងសេចក្តីក្តៅក្រហាយថា អាត្មាអញឥតលាភទេតើ លាភរបស់អាត្មាអញគ្មានសោះទេហ្ន៎ តាំងអត្តភាពជាមនុស្សសោតក៏អាត្មាអញបានដោយកម្រ មិនមែនអាត្មាអញបានដោយងាយទេ (ឥឡូវ) អាត្មាអញខឹងអន់ចិត្តប្រាថ្នានឹងខាទ បានជាក់ប្រតិកូតាំងឡាយឲ្យពេញហើយ ដើរចៀសចេញទៅនិយាយថា លោកទាំងឡាយចូរនាន់ក្តីនាំយកទៅក្តី (ក៏តាមចិត្តចុះ) កម្មដែលអាត្មាអញបានសន្សំមកជាច្រើនហើយ (នេះ) នឹងជាបុណ្យ ឬជាបាបហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន កម្មដែលខ្ញុំព្រះអង្គបានសន្សំមកជាច្រើនហើយ (នេះ) តើនឹងជាបុណ្យឬជាបាប ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ កិកូសង្ឃមានព្រះពុទ្ធជាប្រធានដែលអ្នកបានទំមន្តដើម្បីនាន់ក្នុងថ្ងៃស្អែកដោយចំណែកណា ចំណែកដែលអ្នកបានសន្សំហើយនោះក៏ជាបុណ្យយ៉ាងច្រើន គ្រាប់ថ្យមួយគ្រាប់ ។ របស់អ្នកដែលកិកូមួយរូប ។ ខ្ជួលហើយដោយចំណែកណា ចំណែកដែលអ្នកបានសន្សំនោះក៏ជាបុណ្យយ៉ាងច្រើនហើយ ឈ្មោះថាអ្នកឯងបានប្រព្រឹត្តយកឋានសួគ៌ហើយ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះក៏គិតថា ប្រហែលជាលាភរបស់អាត្មាអញហើយ ប្រហែល

ឥមាំ ភិក្ខវេ មយា បុញ្ញំ បសុតំ សត្តា ភិក្ខវេ មេ អារក្ខាតំ
មាឡោ ឧទក្កោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា
បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ
និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា
ភិក្ខូ បដិបុច្ឆិ សច្ចំ ភិក្ខវេ ភិក្ខូ អញ្ញត្រ និមន្តិតា
អញ្ញស្ស កោដ្ឋយាកុំ បរិភុញ្ជន្តីតិ ។ សច្ចំ ភគវាតិ ។
វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិ-
សា អញ្ញត្រ និមន្តិតា អញ្ញស្ស កោដ្ឋយាកុំ បរិភុញ្ជិស្សន្តិ
នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិ-
ត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ
អញ្ញត្រ និមន្តិតេន អញ្ញស្ស កោដ្ឋយាកុ បរិភុញ្ជិតព្ពា
យោ បរិភុញ្ជេយ្យ យថាធម្មោ ការេតព្ពោតិ ។

ជាអាត្មាអញបានអត្តភាពជាមនុស្សល្អហើយ ប្រយោលជាអាត្មាអញបាន
សទ្ធាបុណ្យជាច្រើនហើយ ប្រយោលជាឈ្មោះថា អាត្មាអញប្រារព្ធយក
ឋានសួគ៌ហើយ តំមានចិត្តរីករាយស្រស់ស្រាយឡើងក្រោកចាកអាសនៈ
ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណរួចចៀសចេញទៅ ។
ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ
ហើយត្រាស់សួរចំពោះពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថាគេបាននិមន្ត
ពួកភិក្ខុទៅក្នុងត្រកូលដទៃហើយ ភិក្ខុទាំងនោះនៅឆាន់បបរកោដ្ឋរបស់
ត្រកូលឯទៀតវិញ ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះ
ដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀល
ថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ បាននិមន្តក្នុងត្រកូលដទៃ
ហើយ មិនសមបើនឹងទៅឆាន់បបរកោដ្ឋរបស់ត្រកូលឯទៀតសោះ ម្នាល
ភិក្ខុទាំងឡាយ អំពើនេះមិនទាំងឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា
ទេ ។ បេ ។ ទ្រង់តិះដៀលហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំង-
ឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទទួលនិមន្តក្នុងត្រកូលដទៃហើយ
មិនត្រូវឆាន់បបរកោដ្ឋរបស់ត្រកូលឯទៀតទេ ភិក្ខុណាឆាន់ ត្រូវនិយាយដូ
ឲ្យភិក្ខុនោះធ្វើតាមធម៌ (គឺឲ្យសំដែងអាបត្តិចេញ) ។

[๑๑๓] อถโข ภควา อนฺตรวาสเก ยถาภิรนฺตํ วิหริตฺวา เยน ภคฺควา เตน จาริกํ ปกฺกามิ มหตา ภิกฺขุสงฺฆेน สทฺธึ อฑฺฒเตลเสหิ ภิกฺขุสเตหิ ฯ เตน โข ปน สมเยน เวฬุวคามโก[๑] กจฺฉาโก ภคฺควา อนฺตรวาสกํ อุทฺทิสฺส อุปฏฺฐากปฺปฏิปตฺติยา เหมนฺตปฺปฏิสลฺลาเน สารปฺปตฺโต โหติ ฯ อถ โข ภควา เวฬุวคามกสฺส สามนฺตา กจฺฉานํ อุปจงฺกมิ ฯ อทฺทสา โข ภควา เวฬุวคามกสฺส สามนฺตา กจฺฉานํ อารกฺขญฺจ อาวรณญฺจ ปฏิจฺจ มตฺตา ปฏิลทฺธา อญฺญตรสฺมึ รุกฺขมูเล นิสีทิ ฯ อถ โข เวฬุวคามโก กจฺฉาโก เยน ภควา เตนุปสงฺกมิ อุปสงฺกมิตฺวา ภควนฺตํ อภิวาเทตฺวา เอกมนฺตं อฏฺฐาสิ ฯ เอกมนฺตं ฐิโต โข เวฬุวคามโก กจฺฉาโก ภควนฺตํ เอตทโวจ สาธุ ภนฺเต ภควา เอกมेकสฺส ภิกฺขุโน เอกमेकं กุฏฺฐิกมฺมं อาณาเปตุ ฯ เตนหิ ตฺวं กจฺฉาน เอกंเยว กุฏฺฐิกมฺมं อาหราติ ฯ เอวं ภนฺเตติ โข เวฬุวคามโก กจฺฉาโก ภควโตปฏิสฺสุณิตฺวา เอกंเยว กุฏฺฐิกมฺมं อาหราย เยน ภควา เตนุปสงฺกมิ อุปสงฺกมิตฺวา ภควนฺตํ เอตทโวจ อาหโร ภนฺเต

๑ ม. เวฬุวฺโห ฯ

(๑๑๓) គ្រានោះ ព្រះដ៏មានព្រះភាគគង់នៅក្នុងអន្ធកវិន្ទប្រទេស តាមសមគួរដល់ព្រះអធ្យាស្រ័យហើយ ទ្រង់យាងចេញទៅកាន់ចារិកក្រុងរាជគ្រឹះ មួយអន្ទើដោយកិក្ខុសង្ឃច្រើនប្រមាណមួយពាន់ពីរយហាសិបរូប ។ សម័យនោះឯង បុរសឈ្មោះវេលដ្ឋកច្ចាន បានផ្កុកសុទ្ធតែក្អមស្ករអំពៅពេញរនេះតាំងច្រាំរយហើយ ក៏ចេញចាកក្រុងរាជគ្រឹះទៅតាមផ្លូវឆ្ងាយចំពោះអន្ធកវិន្ទប្រទេស ។ ព្រះដ៏មានព្រះភាគបានទតឃើញវេលដ្ឋកច្ចានដើរមកអំពីចម្ងាយ លុះទតឃើញហើយទ្រង់យាងចៀសអំពីផ្លូវទៅគង់គ្រាមម្លប់ឈើមួយ ។ លំដាប់នោះ វេលដ្ឋកច្ចានបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចឈរនៅក្នុងទីសមគួរ ។ លុះវេលដ្ឋកច្ចានឈរនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់ប្រគេនស្ករអំពៅ១ក្អម ។ ដល់កិក្ខុមួយរូប ។ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះចូរអ្នកឯងទៅយកស្ករអំពៅតែមួយក្អមមកមើលសិន ។ វេលដ្ឋកច្ចានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយយកស្ករអំពៅមួយក្អមដើរចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន

កុម្ភកុម្ភោ កថាហាំ កន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កថ្នាន កំក្ខំ កុម្ភំ ខេបាហីតិ ។ ឃំ កន្តេតិ ខោ វេលដ្ឋោ កថ្នាឧោ កកវតោ បដិស្សុណិត្វា កំក្ខំ កុម្ភំ ឧត្វា កកវន្តំ ឯតទវោច ឯិដ្ឋោ កន្តេ កំក្ខំ កុម្ភោ ពហុ ចាយំ កុម្ភោ អវសិដ្ឋោ កថាហាំ កន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កថ្នាន កំក្ខំ កុម្ភំ យាវឧតុំ ខេបាហីតិ ។ ឃំ កន្តេតិ ខោ វេលដ្ឋោ កថ្នាឧោ កកវតោ បដិស្សុណិត្វា កំក្ខំ កុម្ភំ យាវឧតុំ ឧត្វា កកវន្តំ ឯតទវោច ឯិដ្ឋោ កន្តេ កំក្ខំ កុម្ភោ យាវឧតុោ ពហុ ចាយំ កុម្ភោ អវសិដ្ឋោ កថាហាំ កន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កថ្នាន កំក្ខ កុម្ភេហិ សន្តប្បេហីតិ ។ ឃំ កន្តេតិ ខោ វេលដ្ឋោ កថ្នាឧោ

ខ្ញុំព្រះអង្គបានយកភ្នួមស្ករអំពៅមកហើយ បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំ
ព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាល
កថ្លាន បើដូច្នោះ អ្នកឯងចូរប្រគេនស្ករអំពៅដល់តិក្ខុទាំងឡាយចុះ ។
វេលាដកថ្លាន ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ
ហើយប្រគេនស្ករអំពៅ ដល់តិក្ខុទាំងឡាយ រួចក្រាបបង្គំទូលព្រះមាន
ព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានប្រគេនស្ករអំពៅ
ដល់ពួកតិក្ខុរួចហើយ តម្បូវស្ករអំពៅនេះនៅសល់ជាច្រើន បពិត្រព្រះអង្គ
ដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា
ម្នាលកថ្លាន បើដូច្នោះ អ្នកឯងចូរប្រគេនស្ករអំពៅដល់ពួកតិក្ខុ ដរាបដល់
អស់ចំណង់ចុះ ។ វេលាដកថ្លានទទួលព្រះបន្ទូលព្រះមានព្រះភាគថា
ព្រះករុណាព្រះអង្គ ហើយបានប្រគេនស្ករអំពៅដល់ពួកតិក្ខុ ដរាបដល់អស់
ចំណង់ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន
ខ្ញុំព្រះអង្គបានប្រគេនស្ករអំពៅដល់ពួកតិក្ខុ ដរាបដល់អស់ចំណង់ហើយ
តែស្ករអំពៅនេះនៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គត្រូវ
ប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកថ្លាន បើដូច្នោះអ្នកឯងចូរ
ឲ្យពួកតិក្ខុធាន់ឆ្អែតស្កប់ស្កល់ដោយស្ករអំពៅចាំងឡាយចុះ ។ វេលាដកថ្លាន

ភគវតោ បដិស្សុណិត្វា តំក្ខុ កុទ្ទឡ្ហំ សន្តប្បេសិ ។
ឯកច្ចេ តំក្ខុ បត្តេបិ រុក្ខេសុ បរិស្សាវនាធំបិ ឥវិកាយោបិ
ឫក្ខេសុ ។ អថខោ វេលដ្ឋោ កច្ចានោ តំក្ខុ កុទ្ទឡ្ហំ
សន្តប្បេត្វា ភគវន្តំ ឯតទវោច សន្តប្បិតា ភន្តេ តំក្ខុ
កុទ្ទឡ្ហំ ពហុ ចាយំ កុទ្ទឡ្ហា អវសិដ្ឋោ កថាមំ
ភន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កច្ចាន វិយាសាធានំ
កុទ្ទឡ្ហំ ឆេហីតិ ។ ឯវំ ភន្តេតិ ខោ វេលដ្ឋោ កច្ចានោ
ភគវតោ បដិស្សុណិត្វា វិយាសាធានំ កុទ្ទឡ្ហំ ឆេត្វា
ភគវន្តំ ឯតទវោច ឆិន្នោ ភន្តេ វិយាសាធានំ កុទ្ទឡ្ហា
ពហុ ចាយំ កុទ្ទឡ្ហា អវសិដ្ឋោ កថាមំ ភន្តេ
បដិបជ្ជាមីតិ ។ តេនហិ ត្វំ កច្ចាន វិយាសាធានំ កុទ្ទឡ្ហំ

ទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយបាន
ញុាំងពួកកិកុឲ្យឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយ ។ កិកុពួក
ខ្លះដាក់ពេញថ្ពាត្រកំមាន រៀបទំាងសម្ពត់តម្រងទឹកកំមាន ដាក់ពេញ
ថង់យាមកំមាន ។ លុះវេលាដ្ឋកថ្ចានបានឲ្យពួកកិកុធាន់ឆ្អែតស្កប់ស្កល់
ដោយស្ករអំពៅទាំងឡាយហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ
ថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យពួកកិកុធាន់ឆ្អែតស្កប់ស្កល់
ដោយស្ករអំពៅទាំងឡាយហើយ តែថាស្ករអំពៅនេះកំនៅសល់ច្រើន
បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះ
អង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរឲ្យស្ករអំពៅដល់
ពួកមនុស្សអ្នកស៊ីដែលផងចុះ ។ វេលាដ្ឋកច្ចានបានទទួលព្រះបន្ទូល
ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយឲ្យស្ករអំពៅ
ដល់ពួកមនុស្សអ្នកស៊ុដែល រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ
ថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យស្ករអំពៅដល់ពួកមនុស្ស
អ្នកស៊ុដែលហើយ តែថាស្ករអំពៅនេះនៅសល់ច្រើន បពិត្រព្រះអង្គ
ដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា
ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរឲ្យស្ករអំពៅដល់ពួកមនុស្សអ្នកស៊ុដែល

យាវទត្ថំ ខេហីតិ ។ ឯវំ វុត្តេតិ ខោ វេលដ្ឋោ កច្ចានោ
ភគវតោ បដិស្សុណិត្វា វិហារទ្វារំ ឃាដេត្វា យាវទត្ថំ
ខាទិត្វា ភគវន្តំ ឯតទវោច និដ្ឋោ ភន្តេ វិហារទ្វារំ
ឃាដេត្វា យាវទត្ថោ ភុត្តោ ថាយំ ឃាដេត្វា អវសិដ្ឋោ
ភោជនោ ភន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កច្ចាន
វិហារទ្វារេ ឃាដេហិ សន្តប្បេហីតិ ។ ឯវំ ភន្តេតិ ខោ
វេលដ្ឋោ កច្ចានោ ភគវតោ បដិស្សុណិត្វា វិហារទ្វារេ
ឃាដេហិ សន្តប្បេសិ ។ ឯកច្ចេ វិហារទ្វារ កោ-
លម្ពេបិ ឃដេបិ ឃរេសុំ បដិភានិបិ ឧច្ឆង្គេបិ ឃរេសុំ ។
អថខោ វេលដ្ឋោ កច្ចានោ វិហារទ្វារេ ឃាដេភិ សន្ត-
ប្បេត្វា ភគវន្តំ ឯតទវោច សន្តប្បិតា ភន្តេ វិហារទ្វារ
ឃាដេហិ ថាយំ ឃាដេត្វា អវសិដ្ឋោ ភោជនោ ភន្តេ

ដកបដល់អស់ចំណង់ចុះ ។ វេលដ្ឋកច្ចានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ឲ្យស្ករអំពៅដល់ពួកមនុស្សអ្នកស៊ីដែល ដកបដល់អស់ចំណង់ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យស្ករអំពៅដល់ពួកមនុស្សអ្នកស៊ីដែល ដកបដល់អស់ចំណង់ហើយ តែថាស្ករអំពៅនេះក៏នៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នេះ អ្នកឯងចូរឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅចាំងឡាយចុះ ។ វេលដ្ឋកច្ចានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅចាំងឡាយ ។ ពួកមនុស្សអ្នកស៊ីដែលខ្វះដាក់ពេញក្រឡក៏មាន ដាក់ពេញភ្នួមក៏មាន រោចនឹងសម្តក់កម្រាលក៏មាន ដក់ពេញថ្នក់ក៏មាន ។ លំដាប់នោះ វេលដ្ឋកច្ចានបានឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅចាំងឡាយ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅចាំងឡាយហើយ តែថាស្ករអំពៅនេះនៅសល់ច្រើន បពិត្រ

ปฏิปชฺชามีติ ฯ ตาหนฺตุ กจฺจาน ปสฺสถิมํ สาเธวเกฯ
เลาเกฯ สมาเกฯ สพฺรหฺมเกฯ สสฺสมณาพฺราหฺมณิ-
ยา ปชาย สาเธวมนุสฺสาย ยสฺส สาฯ กุเฏฺป
ปาโกฺขฺตา สมฺมาปาณิมํ กเรยฺย อญฺเญ ตถาคตสฺส
ก ตถาคตสาวเกสฺส ก เตนหิ ตฺวํ กจฺจาน ตํ กุฏฺปึ
อปหาริเต ก ฌาเปหิ อปฺปาณเกฯ ก อุเกฯ ปิณ-
ฑปาตมีติ ฯ เอวํ ภนฺเตติ โขฯ เวลาฏฺโ กจฺจาโน
ภควโต ปฏิสฺสุณิตฺวา ตํ กุฏฺปึ อปฺปาณเกฯ อุเกฯ
ปิณฺฑปาตสิ ฯ อถโขฯ สาฯ กุเฏฺป อุเกฯ ปกฺกิตฺตา
จิตฺตุชายติ จิตฺติจายติ สนฺถายติ สมฺปฺถายติ
เสยฺยถาปิ ตาม ตาเลา ติวสิ สนฺตาฯ อุเกฯ
ปกฺกิตฺตา จิตฺตุชายติ จิตฺติจายติ สนฺถายติ
สมฺปฺถายติ เอวเมวฯ สาฯ กุเฏฺป อุเกฯ ปกฺกิตฺตา
จิตฺตุชายติ จิตฺติจายติ สนฺถายติ สมฺปฺถา-
ยติ ฯ อถโขฯ เวลาฏฺโ กจฺจาโน สวิกฺตา เลาเมหาฏ-
ตาเลา เยน ภควา เตนุปสงฺกมิ อุปสงฺกมิตฺวา ภควนฺตึ

ព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់
ត្រាស់ថា ម្នាលកច្ចាន ក្នុងលោកព្រមទាំងទេវតា ព្រមទាំងមារ
ព្រមទាំងព្រហ្ម ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ព្រមទាំងសម្មតិ-
ទេពនិងមនុស្ស តថាគតមិនដែលឃើញអ្នកណាមួយនាន់ស្អុះអើតៅហើយ
ស្អុះអើតៅនោះរលួយទៅដោយស្រួលទេ លើកលែងតែតថាគតឬសាវកប-
ន់តថាគតប៉ុណ្ណោះ ម្នាលកច្ចាន បើដូច្នោះ ចូរអ្នកឯងចោលស្អុះអើត
នោះទៅក្នុងទីដែលគ្មានស្មៅស្រស់ ឬចាក់ចោលទៅក្នុងទឹកដែលគ្មានសត្វ
ក៏បាន ។ លុះដួកច្ចានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះ
កុណាព្រះអង្គ ហើយចាក់ចោលស្អុះអើតៅនោះទៅក្នុងទឹកដែលគ្មាន
សត្វ ។ ឯស្អុះអើតដែលលុះដួកច្ចានដាក់ចុះទៅក្នុងទឹកនោះ ក៏លាន់ឮ
សំឡេងថា ចិច្ចិដិ ចិចិដិ ហុយផ្សែងឡើងដេរដាស គួរនាដូចដាវដាល
នង្គ័លនៅហាលថ្ងៃអស់មួយថ្ងៃហើយ បុគ្គលដាក់ចុះទៅក្នុងទឹក រមែងឮ
សំឡេងថា ចិច្ចិដិ ចិចិដិ ហុយផ្សែងឡើងដេរដាសយ៉ាងណាមិញ ស្អុះ
អើតនោះដែលបុគ្គលដាក់ចុះទៅក្នុងទឹកហើយ រមែងឮសំឡេងថា ចិច្ចិដិ
ចិចិដិ ហុយផ្សែងឡើងដេរដាសដូច្នោះដែរ ។ លំដាប់នោះឯង ដួកច្ចាន
មានសេចក្តីសុតចិត្តកើតពីព្រួចអស់ទាំងពេម ហើយចូលទៅគាល់
ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ

អកំឯនេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នស្ស
ខោ វេលដ្ឋស្ស កច្ចានស្ស ភគវា អនុបុព្ពីកថំ កថេសិ
សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ
អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ
បកាសេសិ ។ យទា ភគវា អញ្ញាសិ វេលដ្ឋំ កច្ចានំ
កល្យចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ
អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ
បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យ-
ថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ
បដិគ្គណ្ហេយ្យ ឯវមេវ វេលដ្ឋស្ស កច្ចានស្ស តស្មឹយេ-
វាសនេ វីតំ វិគតមលំ ធម្មចក្ខុំ ឧទបាទិ យំ ឥញ្ចិ សមុ-
ទយធម្មំ សព្ពន្តំ និរោធធម្មន្តិ ។ អថខោ វេលដ្ឋោ
កច្ចានោ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគា-
ឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ
អបរប្បច្ចយោ សត្ថុសាសនេ ភគវន្តំ ឯតទវោច

រួចអង្គុយនៅក្នុងទីសមគួរ ។ លុះវេលុដ្ឋកថ្លានអង្គុយនៅក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់សំដែងអនុបុព្វីកថា គឺទ្រង់ប្រកាសអំពីទាន ១ អំពីសីល ១ អំពីស្ថានសួគ៌ ១ អំពីទោសដ៏លាមកសៅហ្មងរបស់កាមទាំងឡាយ ១ នឹងអានិសង្សក្នុងការចេញចាកកាម ១ ។ លុះណាព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា វេលុដ្ឋកថ្លានមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តស្រស់ស្រាយឡើង មានចិត្តជ្រះថ្លា វេលានោះ ក៏ទ្រង់ប្រកាសធម្មទេសនាដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងប្រកាសចំពោះព្រះអង្គឯង គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ។ គួរនាដូចជាសម្ពត់សស្អាតប្រាសចាកវត្ថុមានពណ៌ខៀវ គួរទទួលទឹកជ្រលក់ដោយល្អយ៉ាងណាមិញ ឯវេលុដ្ឋកថ្លានក៏បានកើតធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកគ្រឿងសៅហ្មង លើអាសនៈនោះឯង ដូច្នេះថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ ក៏តែងរលត់ទៅវិញជាធម្មតា យ៉ាងនោះដែរ ។ គ្រានោះ ដែលវេលុដ្ឋកថ្លានបានឃើញសច្ចធម៌ហើយ បានដល់សច្ចធម៌ហើយ បានដឹងច្បាស់សច្ចធម៌ហើយ បានយាងចុះកាន់សច្ចធម៌ហើយ បានឆ្លងវិចិកិច្ឆា កំចាត់បង់នូវសេចក្តីងឿងឆ្ងល់ ដល់នូវភាវៈជាអ្នកក្លៀវក្លា មិនដឿបុគ្គលដទៃក្នុងសាសនានៃព្រះសាស្តា ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ

อภิกฺกนฺตํ ภนฺเต อภิกฺกนฺตํ ภนฺเต เสยฺยถาปิ ภนฺเต นิกฺกุชฺชิตํ วา อุกฺกุชฺเชยฺย ปฏิจฺฉนฺนํ วา วิวเรยฺย มูฬฺหสฺส วา มคฺคํ อาจิกฺเขยฺย อนฺธกาเร วา เตลปชฺโชตํ ธาเรยฺย จกฺขุมนฺโต รูปานิ ทกฺขนฺตีติ เอวเมวํ ภควตา อเนกปริยาเยน ธมฺโม ปกาสิโต ตาหมปิ ภนฺเต ภควนฺตํ สรณํ คจฺฉามิ ธมฺมญฺจ ภิกฺขุสงฺฆญฺจ อุปาสกํ มํ ภควา ธาเรตุ อชฺชตคฺเค ปาณุเปตํ สรณํ คตนฺติ ฯ

(๑๑๔) อถโข ภควา อายสฺมนฺตญฺจ ปาริสทญฺจ ธมฺมาย เทสยิตฺวา สมาทปยิตฺวา สมุตฺเตชยิตฺวา สมฺปหํสยิตฺวา อุฏฺฐายาสนา ปกฺกามิ ฯ อถ โข ภควติ ปกฺกนฺตมตฺเต อายสฺมา สารีปุตฺโต ภิกฺขู อามนฺเตสิ ฯ ยถา ยถา โข ภิกฺขเว ภควา ธมฺมิกถาย วณฺณิยมาเน อตฺตมนา อเหสุ ตถา ตถา มยมฺปิ ภนฺเต ภควา ธมฺมิกถาย วณฺณิยมาเน อตฺตมนา อมฺหา ฯ ตตฺร ภิกฺขเว ภควา ปฐมเมว ทานกถํ กเถสิ ฯ ทานกถา โข ปเนสา ภิกฺขเว สีลกถา นาม สีลกถา โข ปเนสา ภิกฺขเว สคฺคกถา นาม สคฺคกถา โข ปเนสา ภิกฺขเว กามานมาทีนวกถา นาม กามานมาทีนวกถา โข ปเนสา ภิกฺขเว เนกฺขมฺเม อานิสงฺสกถา นาม ฯ

យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះឲ្យផ្លាស់ឡើង ពុំនោះដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទចាំង ពុំនោះសោតដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេង ឬក៏ដូចជាមនុស្សកាន់ប្រទីបប្រាលបំភ្លឺក្នុងទីងងឹតដោយគិតថា ឲ្យមនុស្សដែលមានភ្នែកភ្លឺមើលឃើញនូវរូបទាំងឡាយយ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ប្រកាសហើយដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះសូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផងថាជាទីពឹងទីរលឹក សូមព្រះដ៏មានព្រះភាគចាំទុកនូវខ្ញុំថាជាឧបាសកអ្នកដល់ (នូវព្រះរតនត្រ័យ) ថាជាទីពឹងស្មើដោយជីវិតតាំងអំពីថ្ងៃនេះជាដើមទៅ ។

(๑๑๔) គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាមលំដាប់បានដល់ទៅក្រុងភជគ្គីនោះ ។ បានឮថា ព្រះមានព្រះភាគគង់ក្នុងវត្តវេឡុវនកលន្ទកនិវាបស្ថានជិតក្រុងភជគ្គីនោះ ។ សម័យនោះឯង ស្តេចអាឡវកៈតែងឡើងជាព្រើនក្នុងក្រុងភជគ្គី ។ ពួកភិក្ខុក៏រង្គើសថា ស្តេចអាឡវកៈព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតចំពោះតែភិក្ខុមានដម្មី ប៉ុណ្ណោះ មិនបានទ្រង់អនុញ្ញាតដល់ភិក្ខុគ្មានដម្មីឡើយ ក៏មិនហ៊ានឆាន់ស្តេចអាឡវកៈ ។

ภควาโต ฝตมตฺถํ อาเทเจสุ ฯ อถุชานามิ ภควา
ภิลานสฺส ภุญฺชิ อภิลานสฺส ภุญฺเชยฺยนฺติ ฯ

(๑๑๕) อถโข ภควา ภชภเต ยถาภิรนฺตํ วิหริตฺวา
เยน ชาณุสฺโสณี เตน จาริกํ ปกฺกามิ มหตา
ภิกฺขุสงฺเฆน สทฺธึ อฑฺฒเตลเสหิ ภิกฺขุเสหิ ฯ
อถโข ภควา อนุปุพฺเพน จาริกํ จรมาโน เยน
ชาณุสฺโสณี พฺราหฺมณคามเก ตทวสริ ฯ อสฺโสสุ โข ชาณุสฺโสณี-
พฺราหฺมณคามเก พฺราหฺมณา ภิร ชาณุสฺโสณี อนุปฺป-
ตฺตเต ฯ อถโข ชาณุสฺโสณีพฺราหฺมณคามเก พฺราหฺมณา เยน
ภควา เตนุปสงฺกมึสุ อุปสงฺกมิตฺวา ภควตา สทฺธึ สมฺโมทึสุ
ปฏิสนฺถารึสุ ฯ ปฏิสนฺถารณีเยน โข ชาณุสฺโสณี-
พฺราหฺมณคามเก พฺราหฺมณา ภควนฺตเมตทโวจุ สาธุ โภ โคตม ภควา
สงฺฆปริวุโต อิมสฺมึ ชาณุสฺโสณีพฺราหฺมณคามเก วสตุ ฯ
อถโข ชาณุสฺโสณีพฺราหฺมณคามเก พฺราหฺมณา ภควตา
สทฺธึ สมฺโมทิตา สมฺปฏิสนฺถริตา สมฺปวาเสสุ

ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្មារអំពៅដល់ភិក្ខុមានជម្ងឺ (អនុញ្ញាត) ទឹកស្មារអំពៅដល់ភិក្ខុគ្មានជម្ងឺ ។

(๑๑๕) លំដាប់នោះ ព្រះមានព្រះភាគទ្រង់គង់ក្នុងក្រុងភគ្គឹនៈតាមសមគួរដល់ព្រះអធ្យាស្រ័យហើយ ទើបយាងចេញទៅកាន់ចារិកនៃជាដលិគ្រាមមួយអន្ទើដោយភិក្ខុសង្ឃច្រើនប្រមាណមួយពាន់ពីរយហាសិបរូប ។ គ្រាកាលព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅជាដលិគ្រាមនោះ ។ ពួកឧបាសកនៅក្នុងជាដលិគ្រាមបានឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់យាងមកដល់ជាដលិគ្រាមហើយ ។ គ្រានោះ ពួកឧបាសកនៅក្នុងជាដលិគ្រាមបាននាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះពួកឧបាសកអ្នកនៅក្នុងជាដលិគ្រាមអង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ ពួកឧបាសកអ្នកនៅក្នុងជាដលិគ្រាម លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យ

